ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍

ស្តីពី

## សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និង លើកទិសដៅផែនការសកម្មភាពប្រចាំឆ្នាំ២០១៨ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧

រៀបចំដោយៈ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## ១. សេចក្តីផ្តើម៖

កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ នាទីស្តីការគណៈរដ្ឋមន្ត្រី រាជធានីភ្នំពេញ មានប្រារព្ធសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងលើកទិសដៅផែនការ សកម្មភាពប្រចាំឆ្នាំ២០១៨ ដែលរៀបចំឡើងដោយអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

អង្គសន្និបាតបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តំណាងក្រសួង ស្ថាប័នទាំង២៩ រាជធានី ខេត្តទាំង២៥ តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងតំណាងសិល្បករ សិល្បការីសរុបប្រមាណ ១៧០នាក់។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ដើម្បីពិនិត្យឡើងវិញនូវការអនុវត្តផែនការយុទ្ធសាស្ត្រប្រចាំឆ្នាំ២០១៧ ដោយបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ និងលើកទិសដៅផែនការសកម្មភាពប្រចាំឆ្នាំ២០១៨ ឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាពជាបន្តទៀត។

## ៣. វិធីសាស្ត្រនៃកិច្ចប្រជុំ៖

កិច្ចប្រជុំនេះ បានប្រព្រឹត្តទៅដោយមានការបង្ហាញជាស្លាយបញ្ចាំង ការបើកឱកាសឱ្យមានជាសំណួរចម្លើយ ការលើកឡើងជាចំណាប់អារម្មណ៍ ការពិភាក្សាពេញអង្គ ក្រោមការដឹកនាំផ្ទាល់របស់ឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

## ៤. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម ឯកឧត្តមវេជ្ជបណ្ឌិត **តៃង តន្នី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីគោលបំណងនៃសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងលើកទិសដៅផែនការសកម្មភាពប្រចាំឆ្នាំ២០១៨របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ការពិនិត្យនូវសកម្មភាព និងផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមក ជាពិសេសការបង្ហាញនូវចំណុចខ្លាំង ចំណុចខ្សោយ ព្រមទាំងការបង្ហាញនូវសកម្មភាពលម្អិតដែលនាំឲ្យយើងទទួលបាននូវភាពជោគជ័យ ដើម្បីឆ្ពោះទៅបញ្ចប់នូវបញ្ហាអេដស៍នាឆ្នាំ២០២៥ ។ អង្គសន្និបាតបានប្រព្រឹត្តទៅតាមរបៀបវារៈដូចខាងក្រោម៖

- ✓ សុន្ទរកថាបើកអង្គសន្និបាតដោយឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ✓ បទបង្ហាញពីសកម្មភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ របស់ក្រសួងផែនការ